# ពាក្យស្នើសុំអាជ្ញាប័ណ្ណបូមទឹក នៅតំបន់គ្រប់គ្រងទឹកជនបទនៃក្រុងដារវិន ដែនដីភាគខាងជើងអូស្ត្រាលី

## Apply for a water extraction licence in Darwin Rural Water Control District (71M)

ទម្រង់ 60:71M:r14A

ទម្រង់នេះប្រើសម្រាប់តែពាក្យសុំអាជ្ញាប័ណ្ណបូមទឹក នៅតំបន់គ្រប់គ្រងទឹកជនបទនៃទីក្រុងដារវិន ដែនដីភាគខាងជើងអូស្ត្រាលី ដែលការបូមទឹកប្រើប្រាស់កន្លងមក មិនតម្រូវឱ្យមានការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ដូចមានចែងក្នុង លិខិតគតិយុត្តិ(ច្បាប់)លេខ14A ។

យោងតាមលិខិតគតិយុត្តិ(ច្បាប់)លេខ14A(1)(e) ឱកាសក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ដោយប្រើទម្រង់ពាក្យសុំនេះនឹងផុតសុពលភាពនៅ**ថ្ងៃទី31 ខែកក្កដា ឆ្នាំ2025** ។

### សេចក្តីណែនាំ (Instructions)

ប្រសិនបើអ្នកមានសំណួរផ្សេងៗ សូមផ្ញើអ៊ីម៉ែលមក water.licensing@nt.gov.au ឬទូរសព្ទលេខ (08) 8999 4455

To ensure efficient assessment and processing of this application:ដើម្បីធានានូវការវាយតម្លៃ និងដំណើរការពិនិត្យពាក្យស្នើសុំប្រកបដោយប្រសិទ្ធិភាព៖

1. សូមឆ្លើយឲ្យបានគ្រប់សំណួរទាំងអស់ដែលតម្រូវឲ្យផ្តល់ចម្លើយ។
2. នៅពេលដែលមានការតម្រូវឲ្យភ្ជាប់ឯកសារមកជាមួយ សូមបំពេញឱ្យបានពេញលេញនូវឈ្មោះឯកសារនៅក្នុងប្រអប់ដែលត្រូវភ្ជាប់នៅក្នុងទម្រង់ពាក្យសុំនេះ។ ប្រសិនបើមានការភ្ជាប់ឯកសារណាមួយដែលជាផ្នែកនៃឯកសារធំ សូមបញ្ជាក់ពីលេខទំព័រពាក់ព័ន្ធនៃឯកសារភ្ជាប់នោះនៅក្នុងទម្រង់ដាក់ពាក្យសុំនេះផងដែរ។
3. សូមធ្វើការត្រួតពិនិត្យឡើងវិញនូវពាក្យស្នើសុំនេះក្រោយពេលបានបំពេញចប់រួចរាល់ រួមទាំងឯកសារភ្ជាប់នានា ដើម្បីធានាឱ្យបានថា សេចក្តីនៃការដាក់ពាក្យសុំនេះ មានលក្ខណៈខ្លីហើយខ្លឹម និងឯកសារភ្ជាប់ត្រូវគ្នារួចរាល់ហើយ ព្រមទាំងត្រូវឱ្យច្បាស់ថា ពិតជាបានបំពេញផ្តល់ព័ត៌មានពាក់ព័ន្ធសព្វគ្រប់ត្រឹមត្រូវ និងច្បាស់លាស់។

### ទីកន្លែង និងរបៀបដាក់ពាក្យស្នើសុំ (Where and how to submit this form)

សូមផ្ញើពាក្យសុំដែលបានបំពេញរួចរាល់ទៅអាសយដ្ឋានអ៊ីម៉ែល water.licensing@nt.gov.au

## អត្ថន័យនៃសញ្ញាសម្គាល់មួយចំនួននៅក្នុងទម្រង់ពាក្យស្នើសុំនេះ (Meaning of icons in this form)

- ⓘ ព័ត៌មានសំខាន់ដើម្បីជួយអ្នកក្នុងការបំពេញទម្រង់ពាក្យស្នើសុំនេះ។
- ✎ បង្ហាញពីការណែនាំសម្រាប់ការបំពេញទម្រង់ពាក្យស្នើសុំនេះ។
- 🗎 បង្ហាញឱ្យដឹងថា ត្រូវការឯកសារ ឬភស្តុតាងគាំទ្រ ដែលត្រូវភ្ជាប់ជាមួយនឹងទម្រង់ពាក្យស្នើសុំនេះ។
- 🕮 បង្ហាញឱ្យដឹងថា មានការពន្យល់ពីនិយមន័យ នៅផ្នែកខាងក្រោមនៃទំព័រ។

## ការជូនដំណឹងស្តីពីការប្រមូលព័ត៌មាន និងឯកជនភាព (Collection notice and privacy)

ព័ត៌មានដែលអ្នកផ្តល់ឲ្យនៅក្នុងពាក្យស្នើសុំនេះ អាចនឹងត្រូវបានយកទៅបោះផ្សាយនៅក្នុងគេហទំព័រអាជ្ញាប័ណ្ណបូមទឹកនៃដែនដីភាគខាងជើងអូស្ត្រាលី។ ប្រសិនបើអ្នកមានសំណួរអ្វី អំពីការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនអ្នក ឬក៏ចង់ចូលមើលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកផ្ទាល់ អ្នកអាចទាក់ទងទៅនាយកដ្ឋានធនធានទឹក នៃក្រសួងបរិស្ថាន ឧទ្យាន និងសន្តិសុខទឹក។ រដ្ឋាភិបាលនៃដែនដីភាគខាងជើងអូស្ត្រាលីអនុលោមតាមគោលការណ៍ស្តីពីព័ត៌មានឯកជនបុគ្គល (Information Privacy Principles) ដែលមានចែងក្នុង

ច្បាប់ស្តីពីព័ត៌មានឆ្នាំ2022 (🕮). សម្រាប់ព័ត៌មានបន្ថែម
សូមចូលមើលគោលនយោបាយស្តីពីឯកជនភាព(privacy policy)របស់យើង (🕮).

## ការទទួលខុសត្រូវរបស់អ្នកដាក់ពាក្យសុំ (Applicant’s responsibilities)

ប្រសិនបើពាក្យស្នើសុំរបស់អ្នកមិនមានព័ត៌មានគ្រប់គ្រាន់ ដែលមិនអាចឱ្យគេធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំបាននោះ ក្រសួងអាចនឹងបញ្ជូនពាក្យស្នើសុំត្រឡប់ទៅវិញ ដើម្បីការបំពេញឡើងវិញ។ សូមប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ដែលបានផ្តល់ជូន ដើម្បីធានាថា លក្ខខណ្ឌតម្រូវទាំងអស់ត្រូវបានបំពេញ និងពាក្យស្នើសុំរបស់អ្នកត្រូវបានបំពេញចប់សព្វគ្រប់។

មានតែពាក្យស្នើសុំដែលបានបំពេញព័ត៌មានគ្រប់គ្រាន់ទេ ដែលអាចឲ្យក្រសួងធ្វើការសម្រេចចិត្តបានយ៉ាងត្រឹមត្រូវ ហើយនឹងត្រូវគេទទួលយក ព្រមទាំងដំណើរការតាមនីតិវិធីបន្តទៀត។

អ្នកត្រូវតែផ្តល់ភស្តុតាង(🗎) ដែលមានរាយឈ្មោះនៅក្នុងបញ្ជី ដើម្បីគាំទ្រដល់ពាក្យស្នើសុំរបស់អ្នក។

---

🕮 https://nt.gov.au/page/copyright-disclaimer-and-privacy
🕮 https://depws.nt.gov.au/consultation-publications/privacy-policy

## អ្នកមានសិទ្ធដាក់ពាក្យស្នើសុំ (Eligibility)

ⓘ ពាក្យស្នើសុំនេះអាចប្រើបានលុះត្រាតែមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោមនេះ។ ប្រសិនបើអ្នកមិនអាចផ្តល់ចម្លើយថា បាទ/ចាស់ ចំពោះសំណួរទាំងអស់ខាងក្រោមនេះទេ អ្នកមិនអាចប្រើទម្រង់ពាក្យស្នើសុំនេះបានឡើយ។

សូមធ្វើការទាក់ទងទៅកាន់ អាជ្ញាធរនីយ័តកម្មធនធានទឹក តាមរយៈលេខទូរសព្ទ 8999 4455 ប្រសិនបើអ្នកចង់ពិភាក្សាអំពីតម្រូវការរបស់អ្នក។

| **1. តើអ្នកមានសិទ្ធក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណបូមទឹកក្រោមដី សម្រាប់សកម្មភាពលើកលែងណាមួយឬទេ? (Are you eligible to apply for a groundwater licence for an excempt activity?)**<br>✎ សូមគូស (✓) ចម្លើយសមស្រប។ | | |
|---|---|---|
| ការស្នើសុំអាជ្ញាប័ណ្ណនេះ គឺបិតនៅតំបន់គ្រប់គ្រងទឹកជនបទនៃដាវិន បិតក្នុងដែនដីភាគខាងជើងអូស្ត្រាលី(🕮)។ | ☐ បាទ/ចាស់ | ☐ ទេ |
| ក្នុងអំឡុងពេលពីថ្ងៃទី7 ខែកក្កដា ឆ្នាំ2015 ដល់ថ្ងៃទី6 ខែកក្កដា ឆ្នាំ2016 អ្នកមានជាប់ពាក់ព័ន្ធធ្វើប្រតិបត្តិការពាណិជ្ជកម្ម ដែលត្រូវពឹងផ្អែក (🕮) ទឹកក្រោមដីនៅទីតាំងដីដែលអ្នកស្នើសុំបូមទឹក។ | ☐ បាទ/ចាស់ | ☐ ទេ |
| ក្នុងអំឡុងពេលពីថ្ងៃទី7 ខែកក្កដា ឆ្នាំ2015 ដល់ថ្ងៃទី6 ខែកក្កដា ឆ្នាំ2016 អ្នក (🕮)បានបូមយកទឹកជាប្រចាំ ពីអណ្តូងខួងមួយ នៅលើដីដែលមានសកម្មភាពពាណិជ្ជកម្មកំពុងធ្វើប្រតិបត្តិការ។ | ☐ បាទ/ចាស់ | ☐ ទេ |
| ក្នុងអំឡុងពេលពីថ្ងៃទី6 ខែកក្កដា ឆ្នាំ2016 មកទល់នឹងពេលដាក់ពាក្យស្នើសុំនេះ អ្នកបាននៅបន្តធ្វើពាណិជ្ជកម្មដដែល (🕮) ដោយពឹងផ្អែកលើទឹកក្រោមដីនៅទីតាំងដីដែលពាណិជ្ជកម្មកំពុងដំណើរការ។ | ☐ បាទ/ចាស់ | ☐ ទេ |
| ក្នុងអំឡុងពេលពីថ្ងៃទី6 ខែកក្កដា ឆ្នាំ2016 មកទល់នឹងពេលដាក់ពាក្យស្នើសុំនេះ អ្នកបានបូមយកទឹកជាប្រចាំ ពីអណ្តូងខួងមួយ នៅលើដីដែលប្រតិបត្តិការពាណិជ្ជកម្មកំពុងដំណើរការ។ | ☐ បាទ/ចាស់ | ☐ ទេ |

---

🕮 **តំបន់គ្រប់គ្រងទឹកជនបទនៃទីក្រុងដាវិន** គឺជាផ្នែកមួយនៃដែនដីដែលប្រកាសដោយរដ្ឋមន្ត្រី តាមជំពូកទី 22 នៃច្បាប់ចុះថ្ងៃទី17 ខែឧសភា ឆ្នាំ1999 និងបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅរាជក្រឹត្យលេខ21 ចុះថ្ងៃទី2 ខែមិថុនា ឆ្នាំ1999។ សម្រាប់ព័ត៍មានបន្ថែម សូមមើលតាមតំណភ្ជាប់នេះ https://nt.gov.au/environment/water/water-resources-of-the-nt/water-control-districts

🕮 **កិច្ចប្រតិបត្តិកាពាណិជ្ជកម្ម** យោងទៅលើអាជីវកម្ម ឬសហគ្រាសដែលធ្វើសកម្មភាពក្នុងគោលដៅរកប្រាក់ចំណេញ។ កិច្ចប្រតិបត្តិការពាណិជ្ជកម្មអាចធ្វើឡើងជាលក្ខណៈបុគ្គលឯកជន, ភាពជាដៃគូសហការ ឬជាសាជីវកម្ម។

🕮 **ជាប្រចាំ** សំដៅទៅលើការបូមយកទឹកជានិច្ចជាកាល ជាផ្នែកមួយនៃកិច្ចប្រតិបត្តិការអាជីវកម្ម ដែលដែលអាចកំណត់ដឹងជាមុនបាន។ ឧទាហរណ៍នៃសកម្មភាពបូមយកទឹកជាប្រចាំអាចរួមមាននៅក្នុងសកម្មភាពប្រចាំឆ្នាំនៃការស្រោចស្រពដំណាំជាទៀងទាត់នៅរដូវប្រាំង ទោះបីជានៅរដូវភ្លៀងមិនមានការប្រើទឹកស្រោចស្រពក្តី។

🕮 **កិច្ចប្រតិបត្តិកាពាណិជ្ជកម្ម** យោងទៅលើអាជីវកម្ម ឬសហគ្រាសដែលធ្វើសកម្មភាពក្នុងគោលដៅរកប្រាក់ចំណេញ។ កិច្ចប្រតិបត្តិការពាណិជ្ជកម្មអាចធ្វើឡើងជាលក្ខណៈបុគ្គលឯកជន, ភាពជាដៃគូសហការ ឬជាសាជីវកម្ម។

# ផ្នែកទី 1 - អំពីអ្នកដាក់ពាក្យសុំ (About the applicant)

**2. តើនរណាជាអ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណនេះ? (Who is the applicant for this licence?)**

ⓘ ឈ្មោះរបស់អ្នកដាក់ពាក្យសុំគឺនឹងមាននៅលើអាជ្ញាប័ណ្ណថាជាអ្នកកាន់កាប់អាជ្ញាប័ណ្ណ។

✎ សូមផ្តល់ព័ត៌មានរបស់បុគ្គល ឬអង្គភាពស្ថាប័នស្របច្បាប់ដែលពាក្យសុំអាជ្ញាប័ណ្ណបូមទឹកនេះ។ ប្រសិនបើសុំអាជ្ញាប័ណ្ណ សម្រាប់អ្នកដាក់ពាក្យសុំរួមគ្នា សូមផ្តល់ព័ត៌មានរបស់អ្នកដាក់ពាក្យទាំងអស់។

| | |
|---|---|
| ឈ្មោះអ្នកដាក់ពាក្យ | |

**3. តើអ្នកដាក់ពាក្យសុំ ជាលក្ខណៈបុគ្គល, អ្នកស្នើសុំរួមគ្នា ឬជាក្រុមហ៊ុនសាជីវកម្ម? (Is the applicant an individual, joint applicant or corporation?)**

✎ សូមគូស (✓) ចម្លើយសមស្រប។

| | | |
|---|---|---|
| ☐ **បុគ្គល** | ☐ **អ្នកដាក់ពាក្យស្នើសុំរួមគ្នា** | ☐ **ក្រុមហ៊ុនសាជីវកម្ម** |

**4. តើអ្នកណាជាអ្នកធ្វើការទំនាក់ទំនងសម្រាប់ការដាក់ពាក្យស្នើសុំនេះ? (Who are your contacts for this application?)**

✎ សូមផ្តល់ព័ត៌មានសម្រាប់អ្នកទំនាក់ទំនងទីមួយ និងអ្នកទំនាក់ទំនងទីពីរ។

| | **អ្នកទំនាក់ទំនងទីមួយ** | **អ្នកទំនាក់ទំនងទីពីរ** |
|---|---|---|
| **គោត្តនាម និងនាម (ឈ្មោះពេញ)** | | |
| **អាសយដ្ឋានតាមប្រៃសណីយ៍** | | |
| **លេខទូរសព្ទទំនាក់ទំនង** | | |
| **អាសយដ្ឋានអ៊ីម៉ែល** ⓘ ការប្រាស្រ័យទាក់ទងនឹងផ្ញើទៅកាន់អ៊ីម៉ែលនេះ | | |

## ផ្នែកទី 2 - ព័ត៌មានអំពីទីតាំងដី (Property information)

**5. តើអាសយដ្ឋានទីតាំងដីដែលកិច្ចប្រតិបត្តិការពាណិជ្ជកម្មដំណើរការបិតនៅទីណា? (What is the physical address of the property on which the commercial undertaking occurs?)**

ⓘ ព័ត៌មាននេះនឹងត្រូវប្រើដើម្បីជាឯកសារយោងនៅក្នុងពាក្យស្នើសុំរបស់អ្នក ដោយបញ្ជាក់ពីទីតាំងដីថាបិតនៅក្នុងរង្វង់តំបន់គ្រប់គ្រងទឹកជនបទនៃទីក្រុងដារវិន។

✎ សូមផ្តល់ព័ត៌មាននៃទីតាំងដីដែលកិច្ចប្រតិបត្តិការពាណិជ្ជកម្មកំពុងដំណើរការ និងទីកន្លែងដែលត្រូវបូមយកទឹក។
សូមកុំដាក់បញ្ចូលអាសយដ្ឋានចុះបញ្ជីនៃអាជីវកម្ម ឬសាជីវកម្ម លើកលែងតែអាសយដ្ឋាននោះ គឺជាអាសយដ្ឋាននៃទីតាំងដែលអាជីវកម្មប្រព្រឹត្តទៅ។

| | | | |
|---|---|---|---|
| **អាសយដ្ឋានផ្លូវ**<br>(លេខ/ឈ្មោះ/តំបន់) | | | |
| **Parcel number**<br>**លេខក្បាលដី** | | **Location/Region**<br>**ទីតាំង/តំបន់** | |

🗎 ផ្តល់ផែនទីនៃទីតាំងដី ដែលកំណត់ច្បាស់លាស់៖

- ដី (នៅជិតផ្លូវនិង/ឬទីតាំងដែលមានអ្វីសំខាន់គួរកត់សម្គាល់)
- មានលំនៅដ្ឋាន(មួយចំនួន)របស់ប្រជាពលរដ្ឋមូលដ្ឋានឬទេ
- ផ្ទៃដីប្រើប្រាស់សម្រាប់កិច្ចប្រតិបត្តិការពាណិជ្ជកម្ម
- អណ្តូងខួងយកទឹកដែលមានស្រាប់ (រួមបញ្ចូលទាំងលេខចុះបញ្ជីនៃម៉ាស៊ីនខួង ប្រសិនបើមាន)

**6. តើខាងក្រោមនេះ ឃ្លាមួយណាដែលត្រឹមត្រូវជាងគេក្នុងការបង្ហាញពីសិទ្ធរបស់អ្នកក្នុងការប្រើប្រាស់ដីខាងលើនេះ? (Which of the following is the most accurate description of your right to access the land described above?)**

✎ សូមគូស (✓) ចម្លើយសមស្រប ដោយភ្ជាប់មកជាមួយនូវឯកសារជាភស្តុតាង ដូចដែលបានរៀបរាប់។

| ខ្ញុំគឺជា: | គូស (✓) | 🗎 ភស្តុតាងដែលត្រូវការ |
|---|---|---|
| ម្ចាស់ដី | ☐ | ច្បាប់ចម្លងនៃប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធរបស់អ្នក |
| អ្នកដែលបានទទួលសិទ្ធកាន់កាប់ដី (🕮) | ☐ | ច្បាប់ចម្លងនៃលិខិតប្រគល់សិទ្ធ<br>ច្បាប់ចម្លងនៃលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរ និងច្បាប់ចម្លងនៃលក្ខខណ្ឌនៃការអនុញ្ញាត |
| ផ្សេងៗ សូមបរិយាយបញ្ជាក់ | ☐ | ឯកសារភស្តុតាងពាក់ព័ន្ធ |

🕮 **អ្នកដែលបានទទួលសិទ្ធកាន់កាប់ដី** អាចរួមបញ្ចូលទាំង អ្នកជួល, ភតិកៈ ឬអ្នកជួលបន្ត

# ផ្នែកទី 3 - សំណួរស្តីពីប្រតិបត្តិការពាណិជ្ជកម្មដែលតម្រូវឱ្យមានការប្រើប្រាស់ទឹកក្រោមដី (Questions about the commercial undertaking requiring groundwater)

**7. តើស្ថានភាពចុះបញ្ជីនៃកិច្ចប្រតិបត្តិការពាណិជ្ជកម្មរបស់អ្នកមានលក្ខណៈយ៉ាងដូចម្តេច? (What is the registered status of your commercial undertaking?)**

ⓘ ព័ត៌មាននេះនឹងត្រូវបានប្រើដើម្បីបញ្ជាក់ថា អ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យក្នុងការមានសិទ្ធយកទឹកក្រោមដីសម្រាប់ធ្វើប្រតិបត្តិការពាណិជ្ជកម្មណាមួយ។ អ្នកត្រូវតែផ្តល់យ៉ាងហោចណាស់បញ្ជីឯកសារភ្ជាប់ឱ្យបានមួយច្បាប់ក្នុងចំណោមឯកសារដែលមានរៀបរាប់នៅលើបញ្ជីដើម្បីគាំទ្រដល់ពាក្យស្នើសុំរបស់អ្នក។

✎ សូមគូស (✓) ចម្លើយសមស្រប

| | |
|---|---|
| ☐ **ពាណិជ្ជកម្មដែលបានចុះបញ្ជី**<br><br>លេខABN:______________________<br><br>🗎 ភ្ជាប់មកជាមួយនូវឯកសារសម្រង់ឈ្មោះអាជីវកម្មនាពេលបច្ចុប្បន្ន | ☐ **សាជីវកម្ម**<br><br>លេខACN:______________________<br><br>🗎 ភ្ជាប់មកជាមួយនូវឯកសារសម្រង់ក្រុមហ៊ុនបច្ចុប្បន្នមួយច្បាប់ពី ASIC |

☐ **ពុំមែនជាសាជីវកម្មឬ អាជីវកម្មដែលបានចុះបញ្ជី?**

🗎 សូមផ្តល់ព័ត៌មានដើម្បីគាំទ្រដល់ការដាក់ពាក្យសុំរបស់អ្នកដែលថាសកម្មភាពរបស់អ្នកគឺជាកិច្ចប្រតិបត្តិការពាណិជ្ជកម្ម

**8. តើកិច្ចប្រតិបត្តិការពាណិជ្ជកម្មប្រភេទអ្វីដែលកំពុងប្រព្រឹត្តទៅនាពេលបច្ចុប្បន្ននៅលើដីនោះ? (What type of commercial undertaking currently occurs on the land?)**

✎ ផ្តល់ព័ត៌មានពីអាជីវកម្ម ឬសកម្មភាពនានាដែលធ្វើឡើងជាផ្នែកមួយនៃកិច្ចប្រតិបត្តិការពាណិជ្ជកម្ម។ សកម្មភាពទាំងនេះអាចរួមទាំង: សេចក្តីសង្ខេបអំពីអាជីវកម្ម, ការប៉ាន់ប្រមាណនៃទំហំដីប្រើសម្រាប់ធ្វើអាជីវកម្ម, ប្រភេទនៃដំណាំ, ចំនួនមនុស្សធ្វើការ និងការប៉ាន់ប្រមាណពីបរិមាណទឹកប្រើប្រាស់ប្រចាំឆ្នាំ។ ប្រសិនបើកិច្ចប្រតិបត្តិការពាណិជ្ជកម្មនេះបានដំណើរការអស់មួយរយៈកាលមកហើយ សូមផ្តល់ព័ត៌មានទៅតាមដំណាក់កាលនីមួយៗនៅក្នុងដំណើរការអភិវឌ្ឍន៍អាជីវកម្ម។ ប្រសិនបើអ្នកមិនច្បាស់អំពីកាលបរិច្ឆេទជាក់ស្តែង សូមផ្តល់នូវកាលបរិច្ឆេទប៉ាន់ស្មានដែលសមរម្យ។

🗎 ផ្តល់ភស្តុតាងនៃកិច្ចប្រតិបត្តិការពាណិជ្ជកម្មដែលកំពុងតែដំណើរការ។ ឧទាហរណ៍រួមមាន:

- រូបថតមួយចំនួននៃការប្រើប្រាស់ដី
- ព័ត៌មាននៃដំណាំសម្រាប់ឆ្នាំនីមួយៗ
- ការរៀបចំដំឡើង និងដំណើរការនៃហេដ្ឋារចនាសម្ព័ន្ធ

| 9. **តើកិច្ចប្រតិបត្តិការពាណិជ្ជកម្មមានការផ្លាស់ប្តូរឬទេតាំងពីឆ្នាំ2016មក? (Has the commercial undertaking changed since 2016?)**<br>✎ សូមគូស (✓) ចម្លើយសមស្រប |
|---|
| ☐ ទេ, កិច្ចប្រតិបត្តិការពាណិជ្ជកម្មមិនមានការផ្លាស់ប្តូរទេ តាំងពីឆ្នាំ **2016**មក។ |
| ☐ បាទ/ចាស់, កិច្ចប្រតិបត្តិការពាណិជ្ជកម្មបានមានការផ្លាស់ប្តូរ។<br>✎ ចូររៀបរាប់ពីរបៀបដែលកិច្ចប្រតិបត្តិការពាណិជ្ជកម្មបានផ្លាស់ប្តូរ។ ឧទាហរណ៍៖ ការផ្លាស់ប្តូរការនៃដំណើរការអាជីវកម្ម, ផលិតកម្មមានការកើនឡើង, ការកែតម្រូវការដាំដុះ និងកាលវិភាគនៃការស្រោចស្រព, ឬការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ |

🗎 ភ្ជាប់មកជាមួយនូវរូបថតនានា ឬរូបភាពនៃដី ដែលបង្ហាញពីកិច្ចប្រតិបត្តិការពាណិជ្ជកម្មមុនថ្ងៃទី6 ខែកក្កដា ឆ្នាំ2016។ ប្រសិនបើគ្មានរូបភាពទេ សូមផ្តល់ភស្តុតាងបញ្ជាក់នូវការថ្លែងបង្ហាញខាងលើ ដែលអាចរួមបញ្ចូល៖ ព័ត៌មានពីអាជីវកម្ម, និងផែនការអាជីវកម្មចាប់តាំងពីឆ្នាំ2016មកដល់បច្ចុប្បន្នកាល, ព័ត៌មានពីការរៀបចំដំឡើង និងដំណើរការនៃហេដ្ឋារចនាសម្ព័ន្ធដែលបានប្រើក្នុងកិច្ចប្រតិបត្តិការអាជីវកម្ម។

## ផ្នែកទី 4 - សំណួរអំពីការប្រើទឹកក្រោមដីសម្រាប់កិច្ចប្រតិបត្តិការពាណិជ្ជកម្ម (Questions about groundwater use for the commercial undertaking)

| 10. **សម្រាប់កិច្ចប្រតិបត្តិការពាណិជ្ជកម្មខាងលើ តើត្រូវការទឹកបរិមាណប៉ុន្មានក្នុងមួយឆ្នាំៗ? (How much water is required each year for the above commercial undertaking?)**<br>✎ សូមផ្តល់បរិមាណទឹកគិតជាគីឡូលីត្រ ឬមេហ្គាលីត្រ (🕮) ដែលស្នើសុំសម្រាប់ការប្រើប្រាស់ក្នុងមួយ ឆ្នាំៗ។ |
|---|
| |

🕮 រង្វាស់ខ្នាត ដើម្បីរៀបរាប់ពី **បរិមាណទឹក** ជាធម្មតារួមមាន គីឡូលីត្រ(KL) និងមេហ្គាលីត្រ(ML)។ មួយគីឡូលីត្រស្មើនឹង 1000លីត្រ និងមួយមេហ្គាលីត្រ ស្មើនឹងមួយលានលីត្រ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីបរិមាណទឹក សូមចូលទៅមើលតាមតំណភ្ជាប់នេះ https://depws.nt.gov.au/?a=589477

**11. តើការបូមយកទឹកមកធ្វើប្រតិបត្តិការពាណិជ្ជកម្មនោះ យកចេញពីអណ្តូងខួងណា (ខ្លះ)? (What bore(s) was the water routinely taken from for the commercial undertaking?)**

ⓘ ព័ត៌មាននេះនឹងត្រូវគេប្រើដើម្បីបញ្ជាក់ពីធនធានទឹកនៅលើអាជ្ញាប័ណ្ណទឹក និងអណ្តូងខួង(📖) ដែលគេបូមយកទឹក។

✎ សូមផ្តល់ព័ត៌មានពីអណ្តូងខួងទាំងឡាយដែលគេបូមយកទឹក ដោយរួមទាំងលេខចុះបញ្ជី(RN)នៃអណ្តូងនោះផងដែរ។ ប្រសិនបើអណ្តូងមិនមានលេខចុះបញ្ជីទេ សូមផ្តល់នូវទីតាំង GPS នៃអណ្តូង។

| |
|---|
| |

🗎 សូមភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃរបាយការណ៍អណ្តូង ឬផែនទី ឬប្លង់ទីតាំង ដែលបានគូសតាមមូលដ្ឋានរង្វាស់ដែលបង្ហាញ៖

- ព្រំប្រទល់នៃដី ជាមួយនឹងសូចនាករភូមិសាស្ត្រចំណុចខាងជើង
- ទីតាំងនៃអណ្តូងដែលបានប្រើបូមយកទឹក រួមទាំងទីតាំង GPS

## ផ្នែកទី 5 - ការទទួលស្គាល់ (Acknowledgement)

**12. បញ្ជីសាធារណៈ (Public register)**

ⓘ យោងតាមជំពូក 95 នៃច្បាប់ អធិការធនធានទឹក ត្រូវរក្សាទុកបញ្ជីអាជ្ញាប័ណ្ណបូមទឹក។ បញ្ជីនេះត្រូវផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រក្រសួង និងត្រូវមាន៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកកាន់កាប់អាជ្ញាប័ណ្ណ
- កាលបរិច្ឆេទនៃការផុតសុពលភាពរបស់អាជ្ញាប័ណ្ណ
- ទីតាំងដីដែលបច្ចុប្បន្ននេះកំពុងបូមយកទឹក
- បរិមាណទឹកជាអតិបរមាដែលគេអាចបូមយកប្រចាំឆ្នាំ
- ប្រភពទឹកដែលអាចបូមយកបាន។

អធិការធនធានទឹក នឹងថតចម្លងពាក្យស្នើសុំនេះ ឯកសារភ្ជាប់នានា និងអាជ្ញាប័ណ្ណផ្តល់ជូនទៅដាក់ផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងផងដែរ។

| | | |
|---|---|---|
| ខ្ញុំទទួលយល់ព្រមថា ព័ត៌មានរៀបរាប់ខាងលើនឹងមានដាក់ផ្សាយដោយសេរីនៅលើគេហទំព័ររបស់ក្រសួង។ | បាទ/ចាស ☐ | ទេ ☐ |

ⓘ អធិការធនធានទឹក មានសិទ្ធក្នុងការមិនបញ្ចេញព័ត៌មានបើសិនជាឯកភាពទៅនឹងមូលហេតុស្នើសុំថាជាកិច្ចការសម្ងាត់ផ្នែកពាណិជ្ជកម្ម។ អ្នកអាចដាក់ពាក្យស្នើសុំរក្សាការសម្ងាត់ផ្នែកពាណិជ្ជកម្មដោយមិនបញ្ចេញព័ត៌មានជាសាធារណៈ ដោយប្រើទម្រង់ពាក្យស្នើសុំ(📖) ដែលមានផ្តល់ជូនស្រាប់នៅក្នុងគេហទំព័ររបស់ក្រសួង។

| | | |
|---|---|---|
| ខ្ញុំបានបំពេញ និងភ្ជាប់នូវពាក្យស្នើសុំឲ្យរក្សាទុកមិនបញ្ចេញនូវព័ត៌មានសម្ងាត់ផ្នែកពាណិជ្ជកម្ម។ | បាទ/ចាស ☐ | ទេ ☐ |

---

📖 **អណ្តូងខួង**ទាំងអស់នៅដែនដីភាគខាងជើង ត្រូវតែចុះបញ្ជីជាមួយនឹងអាជ្ញាធរធនធានទឹក។ ព័ត៌មានអំពីអណ្តូងខួងមាននៅតំណភ្ជាប់នេះ www.nrmaps.nt.gov.au/knowyourbore.html.

📖ពាក្យស្នើសុំរក្សាទុកមិនបញ្ចេញព័ត៌មានការសម្ងាត់ពាណិជ្ជកម្ម មាននៅក្នុងតំណភ្ជាប់ https://nt.gov.au/?a=705622

## 13. ការយល់ព្រម (Consent)

| | | |
|---|---|---|
| តើអ្នកយល់ព្រមទទួលការទំនាក់ទំនងបញ្ជូនឯកសារទាក់ទងនឹងពាក្យស្នើសុំនេះ និងអាជ្ញាប័ណ្ណនៅថ្ងៃអនាគតតាមរយៈអាសយដ្ឋានអ៊ីម៉ែល ដែលបានផ្តល់ឲ្យខាងលើនេះឬទេ? | បាទ/ចាស់ ☐ | ទេ ☐ |

## 14. សេចក្តីប្រកាស (Declaration)

ⓘ បុគ្គលដែលមានសមត្ថកិច្ចចំពោះមុនច្បាប់ត្រូវចុះហត្ថលេខានៅក្នុងសេចក្តីប្រកាសនេះ។ ដើម្បីទទួលអាជ្ញាប័ណ្ណ ដោយមានឈ្មោះនៃបុគ្គលនីមួយៗដែលជាដៃគូ ឬចូលរួមអាជីវកម្ម ដៃគូនីមួយៗ ឬអ្នកចូលរួមអាជីវកម្ម ត្រូវចុះហត្ថលេខានៅក្នុងសេចក្តីប្រកាសនេះ។

ខ្ញុំសូមប្រកាសអះអាងថា ព័ត៌មាននៅក្នុងការជូនដំណឹងនេះ និងឯកសារភ្ជាប់ គឺជាការពិត និងត្រឹមត្រូវទៅតាមការយល់ដឹងដ៏ខ្ពស់បំផុតរបស់ខ្ញុំ។

| | អ្នកដាក់ពាក្យសុំទី 1 | អ្នកដាក់ពាក្យសុំទី 2 |
|---|---|---|
| **ឈ្មោះ(អក្សរធំ)** | | |
| **តួនាទី** | | |
| **ហត្ថលេខា** | | |
| **កាលបរិច្ឆេទ** | | |

| បញ្ជីផ្ទៀងផ្ទាត់សម្រាប់អ្នកដាក់ពាក្យសុំ (Applicant checklist)<br>ⓘ ចូរបញ្ជាក់ផ្ទៀងផ្ទាត់ថា អ្នកបានបំពេញទម្រង់បែបបទនៃពាក្យស្នើសុំ និងរួមបញ្ចូលនូវឯកសារភស្តុតាងពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយ | |
|---|---|
| **បង្ហាញប្រាប់នូវចំនួនទំព័រនៃឯកសារភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនេះ** | |
| | |
| ផ្នែកទី 1 - ព័ត៌មានរបស់អ្នកដាក់ពាក្យសុំ | |
| **សំណួរ 3: ព័ត៌មានសម្រាប់ទំនាក់ទំនង** | ☐ |
| ផ្នែកទី 2 - ព័ត៌មានអំពីទីតាំងដី | |
| **សំណួរ 5: ទីតាំងដី**<br>• ផែនទីដីពិស្តារ | ☐ |
| **សំណួរ 6: សិទ្ធតាមច្បាប់ក្នុងការប្រើប្រាស់ដី**<br>• ច្បាប់ចម្លងនៃប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធ ដែលបង្ហាញថា អ្នកគឺជាម្ចាស់ដី ឬ<br>• ច្បាប់ចម្លងនៃកិច្ចសន្យាជួលឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលម្ចាស់ដីអនុញ្ញាតឲ្យប្រើប្រាស់ដី។ កិច្ចសន្យាជួល ឬកិច្ចព្រមព្រៀងជួល ត្រូវតែមានបញ្ចូល៖<br>  ○ ការអនុញ្ញាតឲ្យនៅឬធ្វើកិច្ចការនៅលើទីតាំងដី<br>  ○ ការអនុញ្ញាតឲ្យធ្វើសកម្មភាពទាក់ទងនឹងអាជ្ញាប័ណ្ណ | ☐ |
| ផ្នែកទី 3 - ធ្វើប្រតិបត្តិការពាណិជ្ជកម្ម | |
| **សំណួរ 7: ស្ថានភាពនៃការចុះបញ្ជី**<br>• សម្រង់ឈ្មោះ និងលេខពាណិជ្ជកម្ម (ABN) ឬ<br>• សម្រង់ក្រុមហ៊ុនពី ASIC; សេចក្តីសម្រង់ត្រូវមានរួមបញ្ចូលបណ្តាឈ្មោះអ្នកគ្រប់គ្រងក្រុមហ៊ុន | ☐ |
| **សំណួរ 8: ភស្តុតាងនៃកិច្ចប្រតិបត្តិការពាណិជ្ជកម្ម**<br>• រូបថតនានា ឬរូបភាពនៃដី ដែលបង្ហាញពីសកម្មភាពដែលពឹងផ្អែកទៅលើការប្រើប្រាស់ទឹកក្រោមដីដោយរួមទាំងពេលមុនឆ្នាំ2016<br>• ភស្តុតាងពាក់ព័ន្ធដទៃទៀតដែលបង្ហាញឱ្យឃើញនូវកិច្ចប្រតិបត្តិពាណិជ្ជកម្ម | ☐ |
| **សំណួរ 9: ភស្តុតាងនៃកិច្ចប្រតិបត្តិការពាណិជ្ជកម្មបច្ចុប្បន្ន**<br>• រូបថតនានា ឬរូបភាពនៃការអភិវឌ្ឍ (តាំងពីឆ្នាំ2016មក) | ☐ |
| ផ្នែកទី 4 - ការប្រើទឹកក្រោមដី | |
| **សំណួរ 11: អណ្តូងខួងដែលប្រើ**<br>• របាយការណ៍ពីការប្រើអណ្តូងខួង ឬផែនទី GPS ពិស្តារ | ☐ |